**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០៦០ សហវ.អពដ

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារពេលប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៣

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនលោក លោកស្រីទាំងអស់ ដែលជាម្ចាស់យានយន្តគ្រប់ប្រភេទមេត្តាជ្រាបថា ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៣ ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញប្រកាសលេខ ១៤៤ សហវ.ប្រក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ និងសេចក្តីជូនដំណឹងលេខ ០០៥ សហវ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៣ ដែលត្រូវចាប់ផ្តើមប្រមូលក្នុងរយៈពេល៥ខែ ចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ រហូតដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ ។

ដោយហេតុថា ការអនុវត្តប្រមូលពន្ធឆ្នាំ២០១៣នេះ ពលរដ្ឋគ្រប់រូបមានការមមាញឹកបំពេញកាតព្វកិច្ចបោះឆ្នោតសាកលជ្រើសរើសតំណាងរាស្ត្រក្នុងនីតិកាលទី៥ ដូចនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមពន្យារពេលការប្រមូលពន្ធនេះរហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៣ ។

ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ តទៅ អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យ និងអនុវត្តការផាកពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ ចំពោះម្ចាស់យានយន្តទាំងឡាយណាដែលមានការយឺតយ៉ាវបង់ពន្ធក្រោយថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៣ ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី ដែលជាម្ចាស់យានជំនិះគ្រប់ប្រភេទ ពិតជានឹងយកចិត្តទុកដាក់បំពេញកាតព្វកិច្ចសារពើពន្ធបានល្អប្រសើរជាពុំខាន ។

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**<u>ចម្លងជូន</u> ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-រាជធានី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានពាក់ព័ន្ធ/អង្គភាពពន្ធដារខេត្ត-ខណ្ឌ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798